ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខៈ ០៧៥ MIH / 2016

# ប្រកាស
## ស្តីពី
## បទប្បញ្ញត្តិបច្ចេកទេស CTR 010:2015
## សម្រាប់ផលិតផលទឹកស៊ីអ៊ីវ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ១៤១ MIH/2014 ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សាស្តង់ដារជាតិ
- យោងរបាយការណ៍នៃកិច្ចប្រជុំលើកទី១៤ របស់ក្រុមប្រឹក្សាស្តង់ដារជាតិ នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥

## សម្រេច

**ប្រការ១ៈ** កំណត់បទប្បញ្ញត្តិបច្ចេកទេស CTR 010:2015 សម្រាប់ផលិតផលទឹកស៊ីអ៊ីវ ដែលតម្រូវឲ្យផលិតផលទឹកស៊ីអ៊ីវ ត្រូវអនុលោមតាមស្តង់ដារកម្ពុជា CS 066:2011,Rev.1:2015 សម្រាប់ទឹកស៊ីអ៊ីវ ក្នុងគោលបំណងធ្វើឲ្យកាន់តែប្រសើរឡើងនូវគុណភាពផលិតផល ធានាបាននូវសុវត្ថិភាពដល់អ្នកប្រើប្រាស់ និងលើកកម្ពស់សុខមាលភាព សាធារណៈ។

**ប្រការ២ៈ** បុគ្គលណាមួយដែលផលិត កែច្នៃ នាំចូល ផ្សព្វផ្សាយពាណិជ្ជកម្មលក់ ឬ លក់ផលិតផលទឹកស៊ីអ៊ីវនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសដូចមានចែងក្នុងប្រការ ១ ខាងលើជាដាច់ខាត និងត្រូវមានអាជ្ញាប័ណ្ណ និងមានបិទសញ្ញាស្តង់ដារកម្ពុជានៅលើផលិតផល។




ក្រសួងឧស្សាហកម្មនិងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីម៉ែល: mih.smcabinet@gmail.com